អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប

International School of Siem Reap

# ព័ត៌មានអំពីសាលាបឋមសិក្សាប្រចាំ ខែឧសភា ឆ្នាំ២០២២




សិស្សថ្នាក់ទី៣ និពន្ធរឿង ហើយធ្វើការរឹកហាត់សម្តែងយ៉ាងមានទំនុកចិត្ត។ ចំណែកឯសិស្សថ្នាក់ទី៤ ទី៥ និងទី៦ជាអ្នកទស្សនា។










ការហាមប្រាមដាក់ដបទឹកដែលធ្វើពីកញ្ចក់ព្រោះងាយនឹងបែក និងបង្កគ្រោះថ្នាក់ដល់កូនៗសិស្សានុសិស្សពេលធ្លាក់បែក។





អំឡុងពេលមុនថ្ងៃឈប់សម្រាកដើម្បីអបអរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ កូនៗសិស្សានុសិស្សផ្នែកបឋមទាំងអស់ និងលោកគ្រូ អ្នកគ្រូបានចូលរួមលេងល្បែងកម្សាន្តប្រជាប្រិយដូចជា៖ ទាញព្រ័ត្រ វាយក្អម លាក់កន្សែង និងរាំដណ្តើមកៅអីយ៉ាងសប្បាយរីករាយ។




## ការឈ្នះពានប្រចាំខែមេសា



អបអរសាទរដល់សិស្ស ក្រុម តាព្រហ្ម ដែលបានរកពិន្ទុ និងឈ្នះពានប្រចាំខែមេសា។ ធ្វើបានល្អ អស្ចារ្យ!







ក្នុងខែនេះសិស្សថ្នាក់ទី៤ខិតខំប្រឹងប្រែងរៀនសូត្រចំពោះមុខវិជ្ជាអក្សរសាស្រ្តអង់គ្លេសយ៉ាងខ្លាំង។ ពួកគេសរសេររឿងផ្តោតលើអតីតកាលអំពីអ្វីដែលពួកគេធ្លាប់ឆ្លងកាត់ ធ្លាប់លេង និងធ្លាប់ខ្លាចកាលនៅតូចៗ ដោយចងក្រងតាមលំដាប់លំដោយនៃខ្សែរឿង។ បន្ទាប់មកពួកគេធ្វើការកែសម្រួល និងដាក់ក្នុង Scrapbook Page ។

# អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
# International School of Siem Reap

## ព័ត៌មានអំពីសាលាបឋមសិក្សាប្រចាំ ខែឧសភា ឆ្នាំ២០២២



នៅសប្តាហ៍ក្រោយនេះ គឺជាសប្តាហ៍ប្រឡងវាយតម្លៃដើម្បីបញ្ចប់កឆ្នាំ ឆ្នាំសិក្សា ២០២១-២០២២។ សិស្សានុសិស្សទាំងអស់ពីថ្នាក់ទី១ដល់ទី៦នឹងចាប់ផ្តើមអង្គុយធ្វើតេស្តលើវិញ្ញាសា សរសេរ អាន គណិតវិទ្យា និងនព្វន្ធ ចាប់ថ្ងៃចន្ទទី០៩ ដល់ថ្ងៃព្រហស្បត៏ទី១២ ខែឧសភា។ លទ្ធផលនៃការប្រឡងនេះសាលានឹងធ្វើការផ្ញើជូនលោក លោកស្រីនៅថ្ងៃសុក្រ ទី០៣ខែមិថុនា ចុងឆ្នាំសិក្សា។ ដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីឲ្យកូនៗសម្រាកឲ្យបានគ្រប់គ្រាន់ ព្រមទាំងជូនពួកគេមកសាលាឲ្យបានទាន់ម៉ោងដើម្បីរៀបចំខ្លួនប្រឡងឲ្យអស់ពីសមត្ថភាព និងលទ្ធផលល្អ។

<u>កម្មវិធី Class Dojo</u>

ប្រសិនបើលោក លោកស្រីមិនទាន់បានបញ្ចូលឈ្មោះកូនៗក្នុងកម្មវិធីទេ លោកគ្រូ អ្នកគ្រូនឹងធ្វើការផ្ញើឯកសារជូនលោក លោកស្រីដើម្បីធ្វើការបញ្ចូលឈ្មោះ។ បន្ទាប់មកលោក លោកស្រីនឹងបានឃើញសម្មភាពសិក្សាប្រចាំសប្តាហ៍ ព័ត៌មានប្រចាំខែ និងព្រឹត្តិការសំខាន់មួយៗចំនួន

សម្រាប់កម្មវិធីខេមរភាសានឹងរៀបចំការប្រឡងឆមាសលើកទី២ ដែលនឹងប្រព្រឹត្តទៅរយៈពេល**៣**ថ្ងៃ នៅ**<u>ថ្ងៃចន្ទទី២៣ ដល់ថ្ងៃពុធទី២៥ ខែឧសភា</u>**ខាងមុខនេះ។

**អបអរសាទរ ដល់សិស្សឆ្នើមប្រចាំខែមេសា!**

លោកគ្រូ អ្នកគ្រូ បន្ទុកថ្នាក់ ព្រមទាំងមិត្តរួមថ្នាក់មានមោទនភាពជាខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេរហូតទទួលបានលទ្ធផលល្អក្នុងខែនេះ។






**វគ្គសិក្សាបំប៉ន (Summer Programme)** រយៈពេល៤សប្តាហ៍ ចាប់ផ្តើមចូលរៀននៅ ថ្ងៃទី០៤ ខែកក្កដា ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ខាងមុខនេះ។ ទទួលចុះឈ្មោះចាប់ពីថ្ងៃនេះតទៅ! បញ្ចុះតម្លៃ ៥% ចាប់ពីថ្ងៃជូនដំណឹង រហូតដល់ចុងខែឧសភា ឆ្នាំ២០២២។ ព័ត៌មានអំពីការចុះឈ្មោះសិក្សា សូមធ្វើការទំនាក់ទំនងមកការិយាល័យរដ្ឋបាលតាមរយៈលេខទូរស័ព្ទ ៖ (0)12 87 87 82 (0)81 87 87 82

**សូមអរគុណ**!




សូមជម្រាបលោក លោកស្រីផងដែរនៅថ្ងៃ**<u>សុក្រទី១៣ ខែឧសភា</u>** សប្តាហ៍ក្រោយនេះជាថ្ងៃដែលលោកគ្រូ អ្នកគ្រូធ្វើការកែរសន្លឹកកិច្ចការប្រឡង ដូចនេះ សិក្សានុសិស្សត្រូវបានសម្រាក០១ថ្ងៃ។